## ➢ ព័ត៌មានទូទៅអំពី លេខាធិការដ្ឋាននៃក្រុមប្រឹក្សាមូលនិធិ ស.អ.

លេខាធិការដ្ឋាននៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវបង្កើតឡើងដោយអនុក្រឹត្យលេខ ១១២អនក្រ.បក ចុះថ្ងៃទី២១ខែកក្កដា ឆ្នាំ២០១៧ ស្តីពី "ការកំណត់យន្តការសម្រាប់គ្រប់គ្រងផែនការ កសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន" ។

លេខាធិការដ្ឋាននៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដែលមានសមាសភាពច្រើនជាង១២រូប ត្រូវបានបង្កើតឡើងដើម្បីជាសេនាធិការ **ក្រុមប្រឹក្សាភិបាលមូលនិធិ ស.អ.** ដែលត្រូវដឹកនាំដោយសមាជិកអចិន្ត្រៃយ៍នៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

### ➢ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាមូលនិធិ ស.អ. មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

១. ពិនិត្យ សិក្សា ស្រាវជ្រាវ និងការវិភាគលើស្ថានភាពនៃការអភិវឌ្ឍវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងរៀបចំសមិទ្ធផលខាងផ្នែកបច្ចេកវិទ្យានិងហិរញ្ញវត្ថុនៃផែនការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ

២. រៀបចំផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដើម្បីពិនិត្យ និងសម្រេច

៣. រៀបចំផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដើម្បីពិនិត្យនិងសម្រេច

៤. រៀបចំផែនការនិងយន្តការអនុវត្ត ការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែងជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដើម្បីពិនិត្យនិងសម្រេច

៥. រៀបចំនិងសម្របសម្រួលការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដើម្បីពិនិត្យនិង សម្រេច

៦. តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍តាមការណែនាំរបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**

៧. លើកយោបល់អំពីការបន្ត ការផ្ទេរ ការផ្អាក និងការបញ្ឈប់គម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដើម្បីពិនិត្យនិងសម្រេច

៨. រៀបចំសេចក្តីព្រាងថវិកាសម្រាប់អនុវត្តផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដើម្បីពិនិត្យនិងសម្រេច

៩. រៀបចំសេចក្តីព្រាងថវិកាប្រចាំឆ្នាំរបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**

១០. ប្រមូលនិងផ្ទៀងផ្ទាត់ការបង់វិភាគទានរបស់ប្រតិបត្តិករទូរគមនាគមន៍ចូលមូលនិធិ **ស.អ.**

១១. ពិនិត្យ ផ្ទៀងផ្ទាត់ ទូទាត់ និងផាត់ទាត់ការប្រើប្រាស់មូលនិធិ **ស.អ.**

១២. រៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សកម្មភាពប្រចាំឆ្នាំស្តីពីការអនុវត្តផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដើម្បីពិនិត្យនិងសម្រេច

១៣. តាមដានលំហូរធនធាននៃមូលនិធិ **ស.អ.** ដែលបានមកពីប្រភពផ្សេងៗទាំងក្នុងនិងក្រៅប្រទេស

១៤. រៀបចំផែនការចំណូលនិងចំណាយជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដើម្បីពិនិត្យនិងសម្រេច
១៥. រាយការណ៍អំពីវឌ្ឍនភាពនៃការប្រើប្រាស់មូលនិធិ **ស.អ.** និងស្នើសុំ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ចាត់វិធានការនានាចំពោះនីតិបុគ្គលដែលទទួលបានមូលនិធិតែមិនអនុវត្តឬអនុវត្តមិនពេញលេញនូវគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍
១៦. ផ្សព្វផ្សាយគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍
១៧. រៀបចំ សម្របសម្រួល និងធ្វើកំណត់ហេតុរាល់កិច្ចប្រជុំពិភាក្សារបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**
១៨. សម្របសម្រួលការងាររដ្ឋបាលទូទៅនិងគ្រប់គ្រងថែរក្សាមូលនិធិ **ស.អ.**
១៩. គ្រប់គ្រងបុគ្គលិកនិងមន្ត្រីទទួលបន្ទុកសម្របសម្រួលការងាររដ្ឋបាលនិងគ្រប់គ្រងមូលនិធិ **ស.អ.**
២០. រាយការណ៍និងផ្តល់អនុសាសន៍ជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** នូវរាល់បញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងមូលនិធិ**ស.អ.** និង
២១. តួនាទីនិងភារកិច្ចផ្សេងទៀតដែល **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ប្រគល់ជូន។

- លេខាធិការដ្ឋាន នៃក្រុមប្រឹក្សាមូលនិធិ **ស.អ.** នឹងទំនាក់ទំនងផ្ទាល់ជាមួយដៃគូសំខាន់ៗ ដូចជា ក្រសួងអប់រំយុវជន និងកីឡា បណ្ដាសាលារៀន និងប្រតិបត្តិករឯកជននានា ដើម្បីទ្រទ្រង់រាល់សកម្មភាពផ្សេងៗ និងផ្តល់ជាធនធាន សម្រាប់អភិវឌ្ឍវិស័យបច្ចេកវិទ្យានៅកម្ពុជា។,

- **ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់អ៊ីម៉ែល** info@cbrd.gov.kh